# ការធ្វើកំណែទម្រង់ ដំណើរការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីបង្ការការកើតមានការឃុំខ្លួនដោយបំពាន

*ដោយមានការជួយឧបត្ថម្ភ ពីការិយាល័យ OHCHR ក្រសួងយុត្តិធម៌ បានណែនាំឲ្យប្រើប្រាស់ទម្រង់មួយថ្មីនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដោយតម្រូវឲ្យចៅក្រមផ្ដល់ហេតុផលផ្លូវច្បាប់ នៅពេលសម្រេចធ្វើការឃុំខ្លួនបុគ្គលណាមួយ ។*



ជនជាប់ឃុំ បានមកដល់តុលាការ ដើម្បីចូលរួមក្នុងសវនាការ

ក្នុងករណីជាច្រើន បុគ្គលដែលត្រូវគេចាប់ខ្លួនពីបទសង្ស័យថាប្រព្រឹត្តអំពើល្មើសច្បាប់ ត្រូវបានឃុំខ្លួនមុនសវនាការ។ ក្នុងប្រទេសកម្ពុជា ការឃុំខ្លួនបណ្ដោះអាសន្ន បានក្លាយជាទម្លាប់អនុវត្តមួយធម្មតាទៅហើយ ជំនួសឲ្យករណីអញ្ញត្រកម្ម។ មានជនជាប់ឃុំខ្លះ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្នរហូតដល់រយៈពេល ១៨ ខែ ក៏សឹងមាន។ ដើម្បីសម្រេចឃុំខ្លួនបុគ្គលណាម្នាក់បណ្ដោះអាសន្ន ចៅក្រមស៊ើបសួរ បានប្រើទម្រង់មួយ ដោយត្រូវគូសក្នុងប្រអប់ដែលមាននៅក្នុងទម្រង់នោះ ប៉ុន្តែមិនបានបញ្ជាក់ហេតុផលផ្លូវច្បាប់ណាមួយ សម្រាប់ការឃុំខ្លួននោះឡើយ។ ការណ៍នេះ បាននាំឲ្យកើតមានករណីឃុំខ្លួនដោយបំពាន។ ម្យ៉ាងវិញទៀត ជនជាប់ឃុំ មិនអាចដឹងពីហេតុផលដែលគេឃុំខ្លួនគាត់ឡើយ។ ក្នុងករណីខ្លះ មានមនុស្សមួយចំនួន ត្រូវបានតុលាការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ហើយក្រោយមក ចៅក្រមទារប្រាក់ពីគ្រួសាររបស់ពួកគាត់ ជាថ្នូរនឹងការដោះលែងឲ្យមានសេរីភាពវិញ។

ក្នុងឆ្នាំ២០១២ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា បានតាមមើលយ៉ាងដិតដល់បន្ថែមទៀត លើទម្លាប់អនុវត្តនេះ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចទៅកាន់តុលាការខេត្តជាច្រើន។ ក្នុងខែមិថុនា ឆ្នាំ២០១២ ការិយាល័យ OHCHR បានរៀបចំសន្និសីទថ្នាក់ជាតិមួយស្ដីពីការអនុវត្តន៍ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានផ្ដោតការយកចិត្តទុកដាក់លើការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងចំណោមបញ្ហាដទៃទៀត។ សន្និសីទនេះ ត្រូវបានសហការរៀបចំជាមួយក្រសួងយុត្តិធម៌ ហើយមានការចូលរួមពីចៅក្រម និងព្រះរាជអាជ្ញាជាន់ខ្ពស់ មេធាវី និងមន្ត្រីនគរបាលយុត្តិធម៌ គ្រប់ខេត្ត ក្រុងទូទាំងប្រទេស។ អនុសាសន៍មួយក្នុងចំណោមអនុសាសន៍ជាច្រើន ដែលសិក្ខាកាមបានអនុម័ត គឺការធ្វើវិសោធនកម្មលើទម្រង់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដែលចៅក្រមប្រើប្រាស់។ ក្នុងអំឡុងពេលនោះដែរ ដោយសហការជាមួយក្រសួងយុត្តិធម៌ ការិយាល័យ OHCHR បានចាប់ផ្ដើមរៀបចំកិច្ចពិភាក្សាតុមូលជាច្រើនស្ដីពីច្បាប់ ដោយមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា និងមេធាវីខេត្ត ក្រុង។ សិក្ខាកាម បានផ្ដល់អនុសាសន៍ដូចគ្នានេះ។ វាជាប្រការសំខាន់ណាស់ ក្នុងការបង្កើតឲ្យមានការយល់ព្រមជាឯកច្ឆន្ទនេះ ក្នុងចំណោមភាគីពាក់ព័ន្ធនានា លើសេចក្ដីត្រូវការ ដើម្បីធ្វើកំណែទម្រង់ដំណើរការឃុំខ្លួនបណ្ដោះអាសន្ន។

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

នៅពេលមានការយល់ព្រមជាឯកច្ឆន្ទហើយ ជំហ៊ានបន្ទាប់ គឺត្រូវធានាថា ក្រសួងយុត្តិធម៌ ដើរតួនាទីដឹកនាំដំណើរការធ្វើកំណែទម្រង់នេះ ដោយមានការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពី ការិយាល័យ OHCHR។ បន្ទាប់ពីមានការប្រឹក្សាយោបល់ពី OHCHR ក្រសួងយុត្តិធម៌ បានអញ្ជើញចៅក្រមជាន់ខ្ពស់មួយចំនួន ក្នុងប្រទេស រួមទាំងចៅក្រមកម្ពុជា ដែលកំពុងបម្រើការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដើម្បីធ្វើសេចក្តីព្រាងទម្រង់ថ្មីនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ប្រការសំខាន់ ត្រូវបញ្ចុះបញ្ចូលក្រសួងយុត្តិធម៌ឲ្យជឿជាក់ថា ក្រសួងគួរតែឲ្យចៅក្រមចូលរួមក្នុងដំណើរការធ្វើកំណែទម្រង់នេះ ដោយសារថា ចៅក្រមខ្លួនគាត់ផ្ទាល់ គឺជាអ្នកត្រូវអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ។ ការចូលរួមដោយផ្ទាល់ និងយ៉ាងសកម្មពីសំណាក់ចៅក្រម អ.វ.ត.ក អាចឲ្យពួកគាត់ ចែករំលែកទម្លាប់អនុវត្តល្អៗ ដែលទទួលបានពី អ.វ.ត.ក ដល់ចៅក្រមកម្ពុជាគ្នាគាត់។ ជាលទ្ធផល ទម្រង់ថ្មីគឺយកតាមគំរូសេចក្តីសម្រេចដែលបានប្រើនៅ អ.វ.ត.ក។ ទម្រង់ថ្មីនេះត្រូវបានដាក់ជូនក្រសួងយុត្តិធម៌សម្រេចក្នុងខែមិថុនា ឆ្នាំ២០១៣។ ក្នុងខែមករា ឆ្នាំ២០១៤ ទម្រង់ថ្មីនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុម័ត និងផ្ញើទៅគ្រប់តុលាការទាំងអស់ទូទាំងប្រទេស។ ក្នុងខែមីនា ឆ្នាំ២០១៤ ក្រសួងយុត្តិធម៌ និងគណៈមេធាវី ដោយមានការឧបត្ថមពីការិយាល័យ OHCHR បានរៀបចំសន្និសីទថ្នាក់ជាតិមួយអំពី "ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងជម្រើសផ្សេងជំនួសការឃុំខ្លួន" ដើម្បីឲ្យចៅក្រម ព្រះរាជអាជ្ញា និងមេធាវី យល់ដឹងអំពីទម្រង់ថ្មីនេះ។

> រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម អង្គ វង្សវឌ្ឍនា បានមានប្រសាសន៍ថា "ទម្រង់ថ្មីនេះ តម្រូវឲ្យចៅក្រមទាំងឡាយ លើកទល្ហីករណ៍ ឬយុត្តិកម្មផ្សេងៗឲ្យបានត្រឹមត្រូវ ចំពោះការឃុំខ្លួនបណ្តោះអាសន្ននេះ។ អស់លោក ត្រូវមានហេតុផល លើកទល្ហីករណ៍ដើម្បីគាំទ្រការសម្រេចរបស់អស់លោក អស់លោក មិនអាចសម្រេចឃុំខ្លួនជនណាម្នាក់ដោយស្រួលៗនោះឡើយ។"

គោលបំណងសំខាន់របស់ទម្រង់ថ្មីនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ គឺដើម្បីបង្ការការឃុំខ្លួនដោយបំពាន។ លក្ខខណ្ឌតម្រូវឲ្យផ្តល់ហេតុផលផ្សេងៗ សម្រាប់ការឃុំខ្លួន គឺដើម្បីពង្រឹង តម្លាភាព និងគណនីយភាពក្នុងដំណើរការក្តីតាមផ្លូវតុលាការ។ លក្ខខណ្ឌតម្រូវនេះ រួមចំណែកផងដែរ ដល់ការកាត់បន្ថយអំពើពុករលួយ ដោយសារថាចៅក្រមទំនងជាមិនសូវហ៊ានឃុំខ្លួនបុគ្គល ព្រោះតែឆ្លៀតឱកាសទាមទារប្រាក់ពីគ្រួសាររបស់ជនរងគ្រោះឡើយ។ នៅទីបំផុត ការណែនាំឲ្យប្រើទម្រង់ថ្មីនេះ អាចជួយកាត់បន្ថយអត្រាច្រើនហួសចំណុះនៃចំនួនជនជាប់ឃុំក្នុងពន្ធនាគារ។